# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ
# ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ
# ២០១៦ - ២០២៦

# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ

## ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ

## ២០១៦-២០២៦

# មាតិកា


មាតិកា........................................................................................ ii

អារម្ភកថា...................................................................................... iv

១- សេចក្តីផ្តើម ................................................................................ ១

២- ចក្ខុវិស័យ ................................................................................ ៣

៣- គោលបំណង ................................................................................ ៤

៤- គោលដៅទាំង៦ ................................................................................ ៤

៥- យុទ្ធសាស្ត្រ ................................................................................ ៥

៥.១- អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ ................................................ ៥

៥.២- កសាងផែនទីផលិតផលភូមិមួយផលិតផលមួយ ................................ ៥

៥.៣- ជំរុញការអភិវឌ្ឍស្ថាប័ននិងធនធានមនុស្សដែលពាក់ព័ន្ធដល់ការងារជំរុញចលនាភូមិមួយផលិតផលមួយ ................................................ ៥

៥.៤- ជំរុញការផ្លាស់ប្តូរផ្នត់គំនិតឲ្យកាន់តែល្អប្រសើរឡើង ................................ ៦

៥.៥- លើកកម្ពស់ការយល់ដឹងពីបទពិសោធនានានៃការជំរុញចលនាភូមិមួយផលិតផលមួយ ................................................ ៦

៥.៦- លើកកម្ពស់ការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ ................................................ ៦

៥.៧- អភិវឌ្ឍសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍផលិតផលភូមិមួយផលិតផលមួយ ..... ៧

៥.៨- អភិវឌ្ឍសមត្ថភាពក្នុងការផលិតនូវផលិតផលកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម ................................................ ៧

៥.៩- លើកកម្ពស់គុណភាពផលិតផលតាមស្តង់ដាផលិតផលភូមិមួយផលិតផលមួយ ................................................ ៧

៥.១០- ការស្វែងរកប្រភពហិរញ្ញប្បទានសម្បទានឬឥណទាន ................................ ៨

៥.១១- លើកកម្ពស់ការអភិវឌ្ឍទីផ្សារនិងការគ្រប់គ្រងអាជីវកម្ម ................................ ៨

៥.១២- បង្កើត ចងក្រង ឬពង្រឹងនិងពង្រីកសមាគម សហគមន៍ជំរុញចលនាភូមិមួយផលិតផលមួយ ................................................ ៨

៥.១៣- លើកកម្ពស់ការចូលរួមរបស់យុវជននិងស្ត្រីក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ ................................................ ៩

៥.១៤- លើកកម្ពស់ការចូលរួមពីបុគ្គលដែលមានជំនាញ មានបទពិសោធ និងប្រជាជនតាមមូលដ្ឋានក្នុងសកម្មភាពចលនាភូមិមួយផលិតផលមួយ ...................... ៩

៥.១៥- ជំរុញអភិវឌ្ឍប្រកបដោយចីរភាព ............................................................ ១០
៦- ផែនការសកម្មភាព ............................................................ ១០
៦.១- ការបង្កើតយន្តការ ............................................................ ១០
៦.២- ការបង្កើតក្របខណ្ឌគតិយុត្ត ............................................................ ១១
៦.៣- ការគាំទ្រហិរញ្ញវត្ថុ ............................................................ ១១
៦.៤- ការបណ្តុះបណ្តាលធនធានមនុស្ស ............................................................ ១១
៦.៥- ដំណើរការអនុវត្តគម្រោង ............................................................ ១២
៧- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ............................................................ ១២
៨- សេចក្តីសន្និដ្ឋាន ............................................................ ១២

# អារម្ភកថា

ក្នុងការដឹកនាំប្រទេសជាតិឆ្លងកាត់ដំណាក់កាលប្រែប្រួលសំខាន់ៗ រាជរដ្ឋាភិបាលកម្ពុជាពិតជាបានដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវជាច្រើនក្នុងការដឹកនាំប្រទេស ដែលនាំឆ្ពោះទៅរកការអភិវឌ្ឍជាលំដាប់ និងបានប្រែក្លាយខ្លួនពីប្រទេសដែលមានស្ថានភាពអន់ថយខាងសេដ្ឋកិច្ច និងមានអត្រាភាពក្រីក្រខ្ពស់ ក្លាយទៅជាប្រទេសដែលមានការអភិវឌ្ឍសេដ្ឋកិច្ច និងនាំកម្ពុជាចាកចេញពីចំណាត់ថ្នាក់ប្រទេសមានចំណូលកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ ជាងនេះទៀតកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលជាងមួយទសវត្សកន្លងមកនេះ ហើយកំណើននេះក៏នៅតែបន្តរយៈពេល៥ឆ្នាំចុងក្រោយ បានធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាត្រូវគេចាត់ទុកថាជាសេដ្ឋកិច្ចខ្លាមួយថ្មីនៅតំបន់អាស៊ី។

ទន្ទឹមនឹងមោទនភាពនៃកំណើនសេដ្ឋកិច្ចនេះ រាជរដ្ឋាភិបាលបាននិងកំពុងធ្វើការកែទម្រង់គ្រប់ផ្នែក និងគ្រប់វិស័យក្នុងទិសដៅដ៏ត្រឹមត្រូវ ហើយការកែទម្រង់នេះក៏បាននិងកំពុងផ្តល់លទ្ធផលផ្លែផ្កាជាបណ្តើរៗដែលធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែល្អប្រសើរឡើង។ ការសម្រេចបាននូវសមិទ្ធផលទាំងអស់នេះ បានរុញច្រានកម្ពុជាឲ្យឈានដល់ដំណាក់កាលនៃការអភិវឌ្ឍថ្មីមួយ ដែលកម្ពុជាត្រូវធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់និងប្រកបដោយចីរភាពសម្រាប់ជាមូលដ្ឋាននៃការបង្កើតការងារនិងឱកាសរកប្រាក់ចំណូលរបស់ប្រជាជន។

ដើម្បីរួមចំណែកក្នុងកំណើនសេដ្ឋកិច្ច រាជរដ្ឋាភិបាលយល់ឃើញថាទស្សនាទាននៃការជំរុញចលនាភូមិមួយផលិតផលមួយ សមស្របដល់ការជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាននៅកម្ពុជា សម្រាប់ជំរុញលើកទឹកចិត្តប្រជាជនឲ្យចូលរួមផលិតនូវវត្ថុធាតុដើម ការកែច្នៃ ឬអភិវឌ្ឍនិងលក់នៅលើទីផ្សារក្នុងនិងក្រៅប្រទេស ធ្វើឲ្យប្រជាជនមានមោទនភាពនិងទទួលបានកិត្តិយសនិងកិត្តិនាមពីផលិតផលដែលខ្លួនបានផលិត។

ឈរលើស្មារតីនេះ ការរៀបចំនិងដាក់ចេញនូវគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ២០១៦-២០២៦ បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការបង្កើតយុទ្ធសាស្ត្រលើកស្ទួយផលិតផលខ្មែរ និងការរួមចំណែកពង្រឹងនិងពង្រីកការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការខិតខំធ្វើឲ្យកម្ពុជា សម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាលនិងតួអង្គពាក់ព័ន្ធទាំងអស់ រួមទាំងវិស័យឯកជននិងដៃគូអភិវឌ្ឍ ជាពិសេសកសិករ សិប្បករ សេវាករ និងឧស្សាហករខ្នាតតូចនិងមធ្យមនៅទូទាំងប្រទេស ក្នុងការអនុវត្តគោលនយោបាយនេះឲ្យសម្រេចបានជោគជ័យ ស្របតាមការចង្អុលណែនាំរបស់រាជរដ្ឋាភិបាល គឺពិតជាមានសារៈសំខាន់ជាទីបំផុតដើម្បីភាពរុងរឿង វឌ្ឍនភាព វិបុលភាពនៃព្រះរាជាណាចក្រកម្ពុជា និងធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

ពិតណាស់ គោលដៅចម្បងនៃគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ គឺសំដៅលើកកម្ពស់ផលិតផលក្នុងស្រុកឱ្យមានគុណភាពខ្ពស់ មានការវេចខ្ចប់បានល្អ មានសោភណភាព និងមានអនាម័យ ដែលជាតម្លៃបន្ថែមទៅលើផលិតផល។ ដូចនេះរាជរដ្ឋាភិបាលសង្ឃឹមថា ជោគជ័យនៃការអនុវត្តគោលនយោបាយនេះនឹងក្លាយទៅជាសារនយោបាយមួយដ៏ខ្លាំងក្លាថែមទៀត ក្នុងការលើកទឹកចិត្តនិងបើកផ្លូវសម្រាប់ជំរុញការផលិតនូវផលិតផលក្នុងស្រុក ទាំងផលិតផលកសិកម្ម សិប្បកម្ម ឧស្សាហកម្ម និងទាំងសេវាកម្ម ដើម្បីជំរុញការប្រើប្រាស់ក្នុងស្រុកនិងការនាំចេញ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ និងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដែលបានដឹកនាំសម្របសម្រួលរៀបចំគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦ ដ៏មានសារៈសំខាន់នេះ និងសូមវាយតម្លៃខ្ពស់ចំពោះការចូលរួមពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធដែលបានសហការនិងប្រឹងប្រែងរួមគ្នា រៀបចំគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយនេះឡើង។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំនិងជឿជាក់លើការប្តេជ្ញាចិត្ត ស្មារតីទទួលខុសត្រូវខ្ពស់ និងកិច្ចសហប្រតិបត្តិការគ្នាដ៏ល្អរបស់ក្រសួង ស្ថាប័នអនុវត្តនៃរាជរដ្ឋាភិបាលកម្ពុជា នឹងជំរុញឱ្យផលិតផលខ្មែរដែលមានសក្តានុពលនៅតាមមូលដ្ឋានភូមិ ឃុំកាន់តែមានគុណភាព សោភណភាព និងតម្លៃបន្ថែមលើផលិតផលទាំងនោះសម្រាប់ទីផ្សារក្នុងនិងក្រៅប្រទេស។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# គោលនយោបាយជាតិ
# ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ
# ២០១៦-២០២៦

## ១- សេចក្តីផ្តើម

ចលនាភូមិមួយផលិតផលមួយ មានចរិតជាការអភិវឌ្ឍសេដ្ឋកិច្ចជនបទនិងការអភិវឌ្ឍចម្រុះនៅតាមសហគមន៍ ដែលចលនានេះមានដើមកំណើតនៅខេត្តអូយតាប្រទេសជប៉ុននាទសវត្សរ៍ឆ្នាំ១៩៧០ ហើយចលនានេះបានក្លាយទៅជាចលនាសកលមួយ ដែលមានបណ្តាប្រទេសកំពុងអភិវឌ្ឍជាច្រើនបានយកទៅអនុវត្តនិងប្រែក្លាយទៅជាចលនាភូមិមួយផលិតផលមួយឱ្យស្របទៅតាមស្ថានភាពភូមិសាស្រ្តសេដ្ឋកិច្ច នយោបាយនិងសង្គមរបស់ប្រទេសនោះ។ ដោយឡែក សាធារណរដ្ឋកូរ៉េបានទទួលរងនូវសង្គ្រាមឧបទ្វីបកូរ៉េដោយបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច និងសង្គមហើយសង្គ្រាមនេះបានបញ្ចប់នៅឆ្នាំ១៩៥៣។ នៅឆ្នាំ១៩៧១ គឺរយៈពេលជិត២០ឆ្នាំក្រោយបន្ទាប់ពីចប់សង្គ្រាមនៅឧបទ្វីបកូរ៉េ សាធារណរដ្ឋកូរ៉េបានចាប់ផ្តើមជំរុញចលនាស្រដៀងគ្នានេះ មានឈ្មោះថា**សាមលអ៊ុនដុង** (Saemaul Undong)ប្រែថា**ចលនាភូមិថ្មី**ដែលបង្កើតបានជាមូលដ្ឋានដ៏ជោគជ័យមួយជូនប្រជាជននៃប្រទេសនេះរហូតមកដល់ពេលបច្ចុប្បន្ន។

ប្រទេសជប៉ុន បានផ្តួចផ្តើមគំនិតនៃចលនាភូមិមួយផលិតផលមួយ នៅទីក្រុងតូចមួយឈ្មោះ **អូយ៉ាម៉ា** នាឆ្នាំ១៩៦១ ក្នុងខេត្តអូយតា ហើយ១៨ឆ្នាំក្រោយមក បទពិសោធដ៏ជោគជ័យនេះ ត្រូវបានប្រទេសជប៉ុនយកមក អនុវត្តជាទ្រង់ទ្រាយធំទូទាំងខេត្តអូយតានៅឆ្នាំ១៩៧៩។

ការជំរុញចលនាភូមិមួយផលិតផលមួយ នៅខេត្តអូយតា ប្រទេសជប៉ុន ពឹងផ្អែកលើគោលការណ៍គ្រឹះសំខាន់៣គឺ ១-គិតជាសកល ដោយធ្វើតាមមូលដ្ឋាន ២-ការពឹងផ្អែកលើខ្លួនឯងនិងការច្នៃប្រឌិតរស់រវើក និង៣-ជំរុញការអភិវឌ្ឍធនធានមនុស្ស។ គោលការណ៍គ្រឹះទាំងបីនេះអាចលើកជាសេចក្តីសង្ខេបដូចខាងក្រោមៈ

**១- គិតជាសកល ដោយធ្វើតាមមូលដ្ឋាន :** សំដៅទៅលើគំនិតដែលស្ថិតនៅជាប់ជាមួយនឹងវប្បធម៌ប្រពៃណីដែលមាននៅតាមមូលដ្ឋាន ហើយពួកគេបង្កើតផលិតផលទាំងឡាយដែលអាចរកទីផ្សារបានទាំងក្នុងនិងក្រៅប្រទេស។

**២- ការពឹងផ្អែកលើខ្លួនឯងនិងការច្នៃប្រឌិតរស់រវើក :** មានន័យថាប្រជាជនក្នុងមូលដ្ឋានអាចសម្រេចចិត្តផលិតនូវផលិតផលនានា ទាំងទំនិញនិងសេវាកម្ម សម្រាប់ចលនាភូមិមួយផលិតផលមួយរបស់ពួកគេដែលក្នុងនោះភូមិមួយ ឬច្រើនអាចជ្រើសយកផលិតផលមួយឬច្រើន។ រដ្ឋបាលមូលដ្ឋានមានភារកិច្ចសម្របសម្រួលផ្នែកបច្ចេកទេសនិងទីផ្សារ។

**៣- ជំរុញការអភិវឌ្ឍធនធានមនុស្ស :** កត្តាជោគជ័យរបស់ភូមិមួយផលិតផលមួយ គឺការអភិវឌ្ឍធនធានមនុស្សហើយចលនានេះនឹងពុំអាចទទួលជោគជ័យបានទេ ប្រសិនបើគ្មានការប្រមើលមើលទៅថ្ងៃមុខនូវអ្នកដឹកនាំតាមមូលដ្ឋានទាំងនោះ។ ដូច្នេះវាជាការចាំបាច់ណាស់ក្នុងការអភិវឌ្ឍសហគមន៍មួយដែលត្រូវឆ្លើយតបប្រកបដោយការច្នៃប្រឌិតរស់រវើក នៅពេលប្រឈមមុខនឹងការលំបាកផ្សេងៗ។

ដោយឡែកនៅកម្ពុជាយើង គំនិតនៃការជំរុញចលនាភូមិមួយផលិតផលមួយឬផលិតផលនៅតាមតំបន់នេះបានកើតមានតាំងពីយូរលង់ណាស់មកហើយ ដោយប្រជាជនខ្មែរមានការឧស្សាហ៍ព្យាយាមចិញ្ចឹមសត្វ ដាំដំណាំ ផលិតនូវវត្ថុធាតុដើមនានា ហើយច្នៃផលិតផលទាំងនោះបានយ៉ាងច្រើនទៅតាមទីកន្លែងផ្សេងៗនិងបានបញ្ជាក់តាមការដាក់ឈ្មោះភូមិ ឃុំ ស្រុក ឬខេត្តមួយចំនួនជាឈ្មោះផលិតផលដែលប្រជាជនដាំ ផលិត ឬអនុវត្តពីដូនតាមក ដូចជាភូមិដើមមៀននិងភូមិចេក(ខេត្តកណ្តាល) ឃុំព្រៃរំដេងនិងឃុំស្លា(ខេត្តតាកែវ) ស្រុកក្រូចឆ្មារ(ខេត្តត្បូងឃ្មុំ) ស្រុករំដួល(ខេត្តស្វាយរៀង) និងកន្លែងផលិតឆ្នាំងដាក់ឈ្មោះខេត្ត គឺខេត្តកំពង់ឆ្នាំង និងកន្លែងសម្បូរត្បូងនិងភ្នំដាក់ឈ្មោះថាខេត្តរតនគីរីជាដើម។

និយមន័យផលិតផលភូមិមួយ ផលិតផលមួយ គឺជាផលិតផលដែលផលិតឡើងដោយប្រជាជនតាមភូមិឋានមួយឬច្រើន ហើយផលិតផលទាំងនោះឆ្លុះបញ្ចាំងពីលក្ខណៈវប្បធម៌ប្រពៃណីតាមបែបបុរាណនិងតាមបែបសម័យទំនើប ដែលផ្តល់នូវកិត្យានុភាពនិងមោទនភាពចំពោះភូមិឋានខ្លួនកំពុងរស់នៅ ហើយផលិតផលទាំងនោះមានសក្តានុពលអាចពង្រឹងនិងពង្រីកបានទាំងបរិមាណ គុណភាពនិងសោភណភាពដើម្បីបង្កើនតម្លៃបន្ថែមក្នុងការជួយបង្កើនប្រាក់ចំណូលដល់ប្រជាជន ហើយជាផលិតផលបានស្នើសុំចូលជាសមាជិកចលនាភូមិមួយផលិតផលមួយ នឹងត្រូវបានទទួលការយល់ព្រមពីគណៈ កម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ។

ក្នុងនីតិកាលទី៣នៃរដ្ឋសភា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រតិភូកម្ពុជាចំនួន២១រូប ទៅទស្សនាភាពជោគជ័យនៃការជំរុញចលនាភូមិមួយផលិតផលមួយ នៅខេត្តអយតា ប្រទេសជប៉ុនពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០១ ដោយបានទៅពិនិត្យនិងស្វែងយល់ពីចលនាភូមិមួយផលិតផលមួយ របស់ខេត្តអយតារហូតឈានទៅបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ នៅឆ្នាំ២០០៦ ក្នុងគោលបំណងជំរុញការផលិត ការកែច្នៃផលិតផលកសិកម្ម សិប្បកម្ម និងសេវាកម្មនានាជាមូលដ្ឋានសម្រាប់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារទាំងក្នុងប្រទេសនិងក្រៅប្រទេស ព្រមទាំងរួមចំណែកបម្រើដល់វិស័យទេសចរណ៍និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។

ឈរលើសក្តានុពលដែលកម្ពុជាមាននៅតាមតំបន់នានាក្នុងប្រទេស ការជំរុញចលនាភូមិមួយផលិតផលមួយពិតជានឹងទទួលបានជោគជ័យដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ ក្នុងពេលដែលប្រទេសជាតិនិងប្រជាជនកម្ពុជា កំពុងទទួលបាននូវសុខសន្តិភាពពេញលេញទូទាំងប្រទេសព្រមទាំងបានជំរុញការអភិវឌ្ឍគ្រប់វិស័យ រួមទាំងវិស័យសេដ្ឋកិច្ចដែលបាន និងកំពុងរីកលូតលាស់នឹងកំណើនភ្ញៀវទេសចរមកកម្ពុជា ដែលនេះគឺជាពេលវេលាមួយសមស្របសម្រាប់បង្កើនផលិតភាពនៃវត្ថុធាតុដើម ការកែច្នៃ ដើម្បីបង្កើនតម្លៃបន្ថែមឬអភិវឌ្ឍផលិតផលខ្មែរឱ្យអស់សក្តានុពលដោយបន្តជំនាញពីបរមបុរាណនិងបច្ចេកវិទ្យាទាន់សម័យ សម្រាប់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារទាំងក្នុងនិងក្រៅប្រទេស។ ហើយតាមរយៈបទពិសោធនៃការជំរុញចលនាភូមិមួយផលិតផលមួយកន្លងមករហូតមកដល់ពេលបច្ចុប្បន្ន គឺទទួលបាននូវការគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងថ្នាក់ជាតិ ក្រោមជាតិ និងដៃគូអភិវឌ្ឍនានា ហើយបានទាមទារឱ្យមានឧបករណ៍ជាមូលដ្ឋានមួយសម្រាប់តម្រង់ទិស និងវាស់វែងពីភាពជោគជ័យនៃការជំរុញចលនានេះ នោះគឺការចងក្រងគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយឡើង។

ម្យ៉ាងទៀត ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ គោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីនានា ជាពិសេសគឺការជំរុញការអនុវត្តយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ច្បាប់ស្តីពីសហគមន៍កសិកម្មនិងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម។ល។ ដែលរាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ធ្វើឱ្យការចាប់ផ្តើមអនុវត្តការងារជំរុញចលនាភូមិមួយផលិតផលមួយឱ្យមានលក្ខណៈច្បាស់លាស់ស៊ីជម្រៅតាមភូមិឋាននីមួយៗ ដើម្បីបង្កើនប្រាក់ចំណូលតាមគ្រួសារ និងអភិវឌ្ឍភូមិ ឃុំនិងសហគមន៍ ធានាដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនឱ្យកាន់តែឆាប់រហ័ស និងលើកកម្ពស់គុណភាពជីវិតប្រជាជនបានកាន់តែប្រសើរឡើង។

ក្នុងន័យនេះ គោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ នឹងចូលរួមចំណែកជួយពន្លឿនកំណើនសេដ្ឋកិច្ចកម្ពុជា ឱ្យមានការវិវឌ្ឍលឿនដូចបណ្តាប្រទេសនានាដែលបានជំរុញចលនានេះទទួលជោគជ័យ ក្នុងនោះការងារជំរុញចលនាភូមិមួយផលិតផលមួយសំដៅសម្រេចឱ្យបានចក្ខុវិស័យរបស់រាជរដ្ឋាភិបាលដែលកម្ពុជា នឹងខិតខំធ្វើឱ្យសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងឆ្នាំ២០៣០និងចំណូលខ្ពស់នៅឆ្នាំ២០៥០ ព្រមទាំងធានានូវការអភិវឌ្ឍប្រកបដោយចីរភាព។

## ២. ចក្ខុវិស័យ

គោលនយោបាយជាតិនេះមានចក្ខុវិស័យផ្តោតលើការលើកកម្ពស់ជីវភាពប្រជាជន ក្នុងការធ្វើឱ្យកម្ពុជាក្លាយទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងលើកកម្ពស់សុខុមាលភាពប្រជាជនឱ្យកាន់តែល្អប្រសើរឡើងធ្វើឱ្យប្រជាជនមានការជឿជាក់លើខ្លួនឯង មានស្មារតីជួយខ្លួនឯង ពេញចិត្តនិង

មោទនភាពខ្ពស់ចំពោះភូមិឋានឬសហគមន៍របស់ខ្លួនដោយសំដៅជំរុញការអភិវឌ្ឍផលិតកម្មជាទំនិញ និងសេវាកម្មនានានៅតាមភូមិឋានឬសហគមន៍ទូទាំងប្រទេស ព្រមទាំងធានាការចូលរួមអភិវឌ្ឍប្រកបដោយចីរភាពលើគ្រប់វិស័យរួមមានសេដ្ឋកិច្ច បរិស្ថាន និងសង្គមកិច្ច ក្នុងកម្រិតភូមិឋាន សហគមន៍ ប្រទេសជាតិ និងសកលលោក។

## ៣- គោលបំណង

គោលនយោបាយជាតិនេះមានគោលបំណងជំរុញការអភិវឌ្ឍខ្សែចង្វាក់ផលិតកម្មជាទំនិញឬសេវាកម្មនៅតាមភូមិឋានឬសហគមន៍ ទាំងការផលិត ទាំងការកែច្នៃ ទាំងការវេចខ្ចប់ និងការអភិវឌ្ឍផលិតផលមួយឬច្រើន ដើម្បីបង្កើនតម្លៃបន្ថែមនិងការស្វែងរកទីផ្សារទាំងក្នុងនិងក្រៅប្រទេស ដើម្បីរួមចំណែកបង្កើនប្រាក់ចំណូលប្រជាជនម្នាក់ៗឱ្យឡើងខ្ពស់ កាត់បន្ថយភាពក្រីក្ររបស់ប្រជាជនឱ្យបានកាន់តែឆាប់រហ័ស ធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ហើយប្រជាជនមានមោទនភាព មានការពេញចិត្តនឹងជីវភាពរបស់ខ្លួន ព្រមទាំងទទួលបាននូវកិត្តិយសពីផលិតផលដែលខ្លួនបានផលិត។

## ៤- គោលដៅ

គោលនយោបាយជាតិនេះមានគោលដៅដូចមានចែងខាងក្រោម៖

**គោលដៅទី១** លើកកម្ពស់ការយល់ដឹងដល់កសិករ សិប្បករ ឧស្សាហករ សេវាករ ឬផលិតករផ្សេងៗទៀត ដើម្បីឱ្យពួកគេផ្លាស់ប្តូរផ្នត់គំនិតកាន់តែល្អប្រសើរឡើង មានការជឿជាក់លើខ្លួនឯងតាមស្មារតីខ្លួនទីពឹងខ្លួន ដោយទទួលយកនូវបច្ចេកវិទ្យាគំនិតច្នៃប្រឌិតថ្មី ធានាដល់ភាពប្រសើរឡើងនៃផលិតកម្ម ទំនិញនិងសេវានានា ដោយម្នាក់ៗគិតថាអាចបង្កើនចំណូលបានជារៀងរាល់ឆ្នាំ នាំឱ្យកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

**គោលដៅទី២** ពង្រឹងនិងពង្រីកកិច្ចសម្របសម្រួលនិងសហប្រតិបត្តិការ ឱ្យអស់លទ្ធភាពជាមួយនឹងក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ វិស័យឯកជន និងបុគ្គល ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិទាំងក្នុងនិងក្រៅប្រទេស ដើម្បីជំរុញចលនាភូមិមួយផលិតផលមួយ។

**គោលដៅទី៣** អភិវឌ្ឍធនធានមនុស្សនិងបច្ចេកវិទ្យា សម្រាប់ចូលរួមក្នុងចលនាភូមិមួយផលិតផលមួយ។

**គោលដៅទី៤** ស្រាវជ្រាវនិងអភិវឌ្ឍផលិតផល វត្ថុធាតុដើម ផលិតផលកែច្នៃ និងបច្ចេកទេសឱ្យមានលក្ខណៈពិសេសស្របតាមតម្រូវការទីផ្សារទាំងក្នុងនិងក្រៅប្រទេស។

**គោលដៅទី៥** អភិវឌ្ឍទីផ្សារ សេវាកម្ម និងការគ្រប់គ្រងអាជីវកម្ម។

**គោលដៅទី៦** ស្វែងរកប្រភពហិរញ្ញប្បទានសម្បទានឬឥណទាន ដើម្បីជំរុញចលនាភូមិមួយផលិតផលមួយ។

## ៥- យុទ្ធសាស្ត្រ

ដើម្បីធ្វើឱ្យសម្រេចបានគោលបំណងនិងគោលដៅនៃគោលនយោបាយជាតិនេះ យុទ្ធសាស្ត្រត្រូវដាក់ចេញមានដូចខាងក្រោម៖

### ៥.១- អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ

- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងយន្តការនានា សម្រាប់គាំទ្រនិងអនុវត្តគោលនយោបាយជាតិស្ដីពីការជំរុញចលនាភូមិមួយផលិតផលមួយ ដោយកំណត់ឱ្យមានកិច្ចសហការ សម្របសម្រួល និងតួនាទី ភារកិច្ចរបស់ភាគីសំខាន់ៗដែលជាប់ពាក់ព័ន្ធ
- ធ្វើឱ្យប្រសើរឡើងនិងពន្លឿនការអនុវត្តគោលនយោបាយជាតិនេះ តាមក្របខណ្ឌច្បាប់ យន្តការពាក់ព័ន្ធនានាដែលមានស្រាប់និងយន្តការថ្មីៗបន្ថែមទៀត
- កសាងផែនការសកម្មភាពជាតិស្ដីពីការជំរុញចលនាភូមិមួយផលិតផលមួយ និងកម្មវិធីនានា ដោយមានសកម្មភាពជាក់លាក់ ពេលវេលា ធនធាន អង្គភាពអនុវត្ត សូចនាករ និងគណនេយ្យភាពនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ។

### ៥.២- កសាងផែនទីផលិតផលភូមិមួយផលិតផលមួយ

- ប្រមូលផ្ដុំនិងចងក្រងផលិតផលទៅតាមប្រភេទ
- ជ្រើសរើសផលិតផលដែលមានសក្ដានុពល ដើម្បីបញ្ចូលក្នុងចលនាភូមិមួយផលិតផលមួយ
- បង្ហាញវឌ្ឍនភាពផលិតផលតាមសូចនាករ ដែលបានកំណត់នៅលើតារាងឬជាផែនទី ឬរូបភាព ឬតាមបែបវិទ្យាសាស្ត្រសម្រាប់បង្ហាញជាទូទៅតាមពេលវេលាកំណត់ជាក់លាក់
- កំណត់សូចនាករវាស់វែងពីវឌ្ឍនភាពផលិតផលភូមិមួយផលិតផលមួយ ដែលបានចូលរួម។

### ៥.៣- ជំរុញការអភិវឌ្ឍស្ថាប័ននិងធនធានមនុស្សដែលពាក់ព័ន្ធដល់ការងារជំរុញចលនាភូមិមួយផលិតផលមួយ

- អភិវឌ្ឍធនធានមនុស្សក្នុងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- អភិវឌ្ឍធនធានមនុស្សតាមក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលចូលរួមជំរុញចលនាភូមិមួយផលិតផលមួយ
- អភិវឌ្ឍធនធានមនុស្សនៅតាមសហគមន៍និងសមាគមដែលចូលរួមក្នុងចលនាភូមិមួយផលិតផលមួយ
- លើកកម្ពស់ការអភិវឌ្ឍស្ថាប័នដែលពាក់ព័ន្ធនឹងការងារជំរុញចលនាភូមិមួយផលិតផលមួយ
- លើកកម្ពស់ការយល់ដឹងនៃការចូលរួមក្នុងការងារជំរុញចលនាភូមិមួយផលិតផលមួយដល់បុគ្គលពាក់ព័ន្ធឬដៃគូអភិវឌ្ឍនានា

- កំណត់សូចនាករវាស់វែងវឌ្ឍភាពនៃការអភិវឌ្ឍស្ថាប័ននិងធនធានមនុស្សដែលពាក់ព័ន្ធដល់ការងារជំរុញចលនាភូមិមួយផលិតផលមួយ។

### ៥.៤- ផ្លាស់ប្តូរផ្នត់គំនិតឱ្យកាន់តែល្អប្រសើរឡើង

- រៀបចំចងក្រងនិងផ្សព្វផ្សាយឧបករណ៍ឬឯកសារគ្រប់ប្រភេទទាក់ទងនឹងការជំរុញលើកទឹកចិត្តផ្លាស់ប្តូរផ្នត់គំនិតឱ្យកាន់តែល្អប្រសើរឡើង សម្រាប់ចូលរួមក្នុងចលនាភូមិមួយផលិតផលមួយ
- រៀបចំទស្សនកិច្ចសិក្សានិងកិច្ចប្រជុំពិភាក្សានានាជាទ្រង់ទ្រាយតូច មធ្យម ឬធំ ដើម្បីជំរុញលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតឱ្យកាន់តែល្អប្រសើរឡើង
- បន្ស៊ីការផ្លាស់ប្តូរផ្នត់គំនិតទៅក្នុងការអនុវត្តជាក់ស្តែង នៃការចូលរួមជំរុញចលនាភូមិមួយផលិតផលមួយ
- កំណត់សូចនាករវាស់វែងពីវឌ្ឍនភាពនៃការផ្លាស់ប្តូរផ្នត់គំនិតឱ្យកាន់តែល្អប្រសើរឡើង។

### ៥.៥- លើកកម្ពស់ការយល់ដឹងពីបទពិសោធនានា នៃការជំរុញចលនាភូមិមួយផលិតផលមួយ

- លើកកម្ពស់ការចែករំលែកបទពិសោធជោគជ័យនិងបញ្ហាប្រឈមនានានៃការងារជំរុញចលនាភូមិមួយផលិតផលមួយ តាមគ្រប់មធ្យោបាយដល់ភាគីពាក់ព័ន្ធទាំងឡាយដែលចូលរួមអនុវត្តចលនាភូមិមួយផលិតផលមួយ
- រៀបចំឱ្យមានទស្សនកិច្ចសិក្សាចលនាភូមិមួយផលិតផលមួយ ទាំងក្នុងនិងក្រៅប្រទេស
- លើកទឹកចិត្តឱ្យប្រើវិធីសាស្ត្រចម្រុះ ដើម្បីស្វែងរកគន្លឹះជោគជ័យនៃការងារជំរុញចលនាភូមិមួយផលិតផលមួយ រួមទាំងការរៀនសូត្រពីការអនុវត្តផ្ទាល់
- កំណត់សូចនាករវាស់វែងពីវឌ្ឍនភាពនៃការយល់ដឹងពីការងារជំរុញចលនាភូមិមួយផលិតផលមួយ។

### ៥.៦- លើកកម្ពស់ការចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ

- កំណត់អត្តសញ្ញាណបុគ្គល អង្គការមិនមែនរដ្ឋាភិបាល សមាគម ដៃគូអភិវឌ្ឍ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងឡាយឱ្យចូលរួមក្នុងចលនាភូមិមួយផលិតផលមួយ
- លើកទឹកចិត្តដល់បុគ្គល អង្គការមិនមែនរដ្ឋាភិបាល សមាគម ដៃគូអភិវឌ្ឍ ក្រសួង ស្ថាប័នពាក់ព័ន្ធ តាមរយៈការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈសំខាន់នៃការជំរុញចលនាភូមិមួយផលិតផលមួយ
- កំណត់សូចនាករវាស់វែងពីវឌ្ឍនភាពនៃការចូលរួមជាលក្ខណៈបុគ្គល អង្គការមិនមែនរដ្ឋាភិបាល សមាគម ដៃគូអភិវឌ្ឍ ក្រសួង ស្ថាប័នពាក់ព័ន្ធ។

### ៥.៧- អភិវឌ្ឍសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍផលិតផលភូមិមួយផលិតផលមួយ

- ប្រមូលផ្តុំនិងចងក្រងអ្នកជំនាញ ឬក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធទាំងឡាយទៅតាមប្រភេទជំនាញ រួមមានវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម ដែលត្រូវចូលរួមក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ
- ជំរុញឲ្យបង្កើតស្ថាប័ន ឬកន្លែងថ្មីចាំបាច់នានា ដើម្បីរួមចំណែកក្នុងការស្រាវជ្រាវ និងអភិវឌ្ឍផលិតផលភូមិមួយផលិតផលមួយ
- ស្រាវជ្រាវរកឧបករណ៍ សម្ភារៈ ឬបច្ចេកវិទ្យាទំនើបៗសមស្របពីគ្រប់ប្រភពសម្រាប់ជំរុញចលនាភូមិមួយ ផលិតផលមួយ
- បណ្តុះបណ្តាលសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍផលិតផល តាមគ្រប់មធ្យោបាយដល់អ្នកផ្តល់សេវា និងអ្នកទទួលផលពីសេវា
- កំណត់សូចនាករវាស់វែងវឌ្ឍនភាព នៃការលើកកម្ពស់សមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍផលិតផលភូមិមួយផលិតផលមួយ។

### ៥.៨- អភិវឌ្ឍសមត្ថភាពក្នុងការផលិតនៅផលិតផលកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម

- រៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពជំនាញផលិតនូវផលិតផលកសិកម្ម ទាំងការដាំដុះដំណាំផ្សេងៗ និងចិញ្ចឹមសត្វគ្រប់ប្រភេទ
- រៀបចំវគ្គបណ្តុះបណ្តាលសមត្ថភាពជំនាញកែច្នៃ ឬអភិវឌ្ឍផលិតផលពីកសិកម្មទៅជាសិប្បកម្ម និងឈានទៅជាវិស័យឧស្សាហកម្មតាមកម្រិតជាក់ស្តែង
- រៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពជំនាញជំរុញផលិតផលទេសចរណ៍ភូមិមួយផលិតផលមួយមានដូចជាទេសចរណ៍ធម្មជាតិ ទេសចរណ៍កែច្នៃ និងទេសចរណ៍វប្បធម៌
- រៀបចំវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពជំនាញ និងសេវាកម្មផ្សេងៗទៀតមិនមែនទេសចរណ៍
- កំណត់សូចនាករនិងវាស់វែងវឌ្ឍនភាពឲ្យបានទៀងទាត់។

### ៥.៩- លើកកម្ពស់គុណភាពផលិតផលតាមស្តង់ដាផលិតផលភូមិមួយផលិតផលមួយ

- រៀបចំ បង្កើត និងចងក្រងស្តង់ដាផលិតផលភូមិមួយផលិតផលមួយ
- ផ្សព្វផ្សាយពីស្តង់ដាផលិតផលភូមិមួយផលិតផលមួយ តាមគ្រប់មធ្យោបាយ
- ពង្រឹងនិងពង្រីកផលិតផលដែលមានស្រាប់តាមស្តង់ដា ដោយរក្សាលក្ខណៈប្រពៃណីទំនៀមទំលាប់ខ្មែរ និងតាមបច្ចេកវិទ្យាទំនើប

- ជ្រើសរើសផលិតផលឈានមុខនៃផលិតផលភូមិមួយផលិតផលមួយ តាមស្តង់ដាបានកំណត់
- ជំរុញឱ្យមានការប្រកួតប្រជែងលើកកម្ពស់គុណភាពផលិតផល តាមគ្រប់រូបភាពជាលក្ខណៈបុគ្គល ក្រុម សមាគម ឬសហគមន៍
- ផ្តួចផ្តើមគំនិតរៀបចំព្រឹត្តការណ៍ទាក់ទាញនានា ដើម្បីជំរុញការលើកកម្ពស់គុណភាព និងស្តង់ដាផលិតផលភូមិមួយផលិតផលមួយ
- កំណត់សូចនាករវាស់វែងពីវឌ្ឍនភាពលើការលើកកម្ពស់គុណភាពផលិតផល តាមស្តង់ដាផលិតផលភូមិមួយផលិតផលមួយ។

### ៥.១០- ការស្វែងរកប្រភពហិរញ្ញប្បទានសម្បទាន ឬឥណទាន

- ប្រមូលផ្តុំចងក្រងស្ថាប័ន អង្គការដៃគូនានាដែលអាចផ្តល់ហិរញ្ញប្បទានសម្បទាន ឬឥណទានទាំងក្នុងនិងក្រៅប្រទេស ដែលមានអត្រាការប្រាក់សមស្រប
- លើកកម្ពស់ការយល់ដឹងពីលក្ខខណ្ឌ និងការប្រើប្រាស់ហិរញ្ញប្បទានសម្បទាន ឬឥណទាននានាដែលមានអត្រាការប្រាក់សមស្របទៅឲ្យផលិតករ សិប្បករ ឧស្សាហករ និងសេវាករ
- លើកកម្ពស់ការចងក្រងនិងសហការជាមួយភាគីពាក់ព័ន្ធក្នុងការរៀបចំរចនាសម្ព័ន្ធឥណទាននៅថ្នាក់សហគមន៍
- ផ្សព្វផ្សាយព័ត៌មានពីស្ថាប័ន អង្គការដែលអាចផ្តល់ហិរញ្ញប្បទានសម្បទាន ឬឥណទាន តាមគ្រប់មធ្យោបាយឱ្យដល់មូលដ្ឋាន ឬសហគមន៍ដែលចូលរួមក្នុងចលនាភូមិមួយផលិតផលមួយ
- កំណត់សូចនាករវាស់វែងវឌ្ឍនភាពក្នុងការស្វែងរកប្រភពហិរញ្ញប្បទានសម្បទាន ឬឥណទាន។

### ៥.១១- លើកកម្ពស់ការអភិវឌ្ឍទីផ្សារនិងការគ្រប់គ្រងអាជីវកម្ម

- កំណត់ប្រភេទទីតាំងសម្រាប់ជំរុញការតាំងបង្ហាញនិងលក់ផលិតផលទាំងក្នុងនិងក្រៅប្រទេស
- បណ្តុះបណ្តាលជំនាញការធ្វើទីផ្សារ
- ស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗសមស្របផ្សេងទៀតសម្រាប់ជំរុញការធ្វើទីផ្សារ
- រៀបចំឧបករណ៍ ឯកសារបណ្តុះបណ្តាល និងផ្សព្វផ្សាយស្តីពីការជំរុញទីផ្សារ
- ផ្សព្វផ្សាយជំនាញនានាសម្រាប់ជំរុញការធ្វើទីផ្សារតាមគ្រប់មធ្យោបាយ
- រៀបចំបណ្តុះបណ្តាលជំនាញគ្រប់គ្រងគម្រោង ការរៀបចំផែនការអាជីវកម្ម
- កំណត់ដៃគូដែលជួយជំរុញការធ្វើទីផ្សារផលិតផលក្នុងស្រុក ភូមិមួយផលិតផលមួយ
- កំណត់សូចនាករវាស់វែងវឌ្ឍនភាពនៃការលើកកម្ពស់នៃការអភិវឌ្ឍទីផ្សារនិងការគ្រប់គ្រងអាជីវកម្ម។

### ៥.១២- បង្កើត ចងក្រង ពង្រឹងនិងពង្រីកសមាគម សហគមន៍ជំរុញចលនាភូមិមួយផលិតផលមួយ

- ប្រមូលចងក្រងទៅតាមប្រភេទនៃសមាគម ឬសហគមន៍ផលិតទាំងឡាយដែលមានស្រាប់ទាំងវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម

- ជំរុញឲ្យមានការបង្កើតថ្មីសមាគម ឬសហគមន៍ផលិតទាំងឡាយតាមជំនាញរួមមាន វិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្មទៅតាមការចាំបាច់នានា
- ជំរុញការចងក្រងជាសម្ព័ន្ធសមាគម ឬសហគមន៍ផលិតទាំងឡាយតាមជំនាញរួមមាន វិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម
- ជ្រើសរើសសមាគម ឬសហគមន៍ជោគជ័យសម្រាប់ធ្វើជាគំរូ ឬជាកន្លែងរៀនសូត្រ
- ចងក្រងសូចនាករវាស់វែងពីវឌ្ឍនភាពនៃការបង្កើត ចងក្រង ឬពង្រឹងនិងពង្រីកសមាគម ឬសហគមន៍ជំរុញចលនាភូមិមួយផលិតផលមួយ។

## ៥.១៣- លើកកម្ពស់ការចូលរួមរបស់យុវជននិងស្ត្រីក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ

- បណ្ដុះបណ្ដាលទស្សនទានចលនាភូមិមួយផលិតផលមួយដល់យុវជននិងស្ត្រីជាលក្ខណៈបុគ្គល ឬជាក្រុមសម្រាប់ចូលរួមក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ
- ប្រមូលផ្ដុំនិងរៀបចំចងក្រងទៅតាមប្រភេទនៃសមាគម ឬសហគមន៍យុវជននិងស្ត្រីដែលមានស្រាប់
- ជំរុញឲ្យមានការបង្កើតថ្មីនៃសមាគម ឬសហគមន៍របស់យុវជននិងស្ត្រី ក្នុងការលើកកម្ពស់ចលនាភូមិមួយផលិតផលមួយ
- បណ្ដុះបណ្ដាលជំនាញពាក់ព័ន្ធនៃការជំរុញចលនាភូមិមួយផលិតផលមួយ ដល់បុគ្គលឬក្រុមយុវជននិងស្ត្រីដែលចូលរួមលើកកម្ពស់ចលនាភូមិមួយផលិតផលមួយ
- ផ្សព្វផ្សាយតាមគ្រប់មធ្យោបាយដើម្បីផ្ដល់ឱកាសដល់យុវជននិងស្ត្រី ឲ្យចូលរួមអនុវត្តការងារជំរុញចលនាភូមិមួយផលិតផលមួយ
- រៀបចំកម្មវិធីនានាដើម្បីលើកទឹកចិត្ត ដូចជាការផ្ដល់រង្វាន់ដល់យុវជននិងស្ត្រីចូលរួមក្នុងការងារជំរុញចលនាភូមិមួយផលិតផលមួយ
- កំណត់សូចនាករវាស់វែងវឌ្ឍនភាព នៃការលើកកម្ពស់ការចូលរួមរបស់យុវជននិងស្ត្រីក្នុងការងារជំរុញចលនាភូមិមួយផលិតផលមួយ។

## ៥.១៤- លើកកម្ពស់ការចូលរួមពីបុគ្គលដែលមានជំនាញ មានបទពិសោធ និងប្រជាជនតាមមូលដ្ឋានក្នុងសកម្មភាពចលនាភូមិមួយផលិតផលមួយ

- ប្រមូលផ្ដុំនិងរៀបចំតារាងបង្ហាញពីជំនាញនានា របស់បុគ្គលទៅតាមវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម ដែលអាចចូលរួមក្នុងការងារជំរុញចលនាភូមិមួយផលិតផលមួយ
- ពង្រឹងនិងពង្រីកសមត្ថភាពជំនាញបន្ថែមទាក់ទងនឹងការងារជំនាញជំរុញចលនាភូមិមួយផលិតផលមួយដល់បុគ្គលជំនាញនិងប្រជាជន

- បែងចែកបុគ្គលជំនាញចុះជួយជំរុញចលនាភូមិមួយផលិតផលមួយទៅតាមជំនាញដែលមាន និងទីកន្លែងសមស្របសម្រាប់ចុះជួយជំរុញចលនាភូមិមួយផលិតផលមួយ
- រៀបចំកិច្ចប្រជុំពិភាក្សានានាដោយទៀងទាត់ពីការងារជំរុញចលនាភូមិមួយផលិតផលមួយ ជាមួយប្រជាជននៅមូលដ្ឋាន
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវយុទ្ធសាស្ត្រជំរុញចលនាភូមិមួយផលិតផលមួយ តាមគ្រប់មធ្យោបាយឱ្យដល់ប្រជាជននៅមូលដ្ឋាន
- កំណត់សូចនាករវាស់វែងវឌ្ឍនភាព នៃការលើកកម្ពស់ការចូលរួមពីបុគ្គលជំនាញនិងប្រជាជនតាមមូលដ្ឋានក្នុងសកម្មភាពចលនាភូមិមួយផលិតផលមួយ។

### ៥.១៥- ជំរុញការអភិវឌ្ឍប្រកបដោយចីរភាព

- លើកកម្ពស់ការយល់ដឹងពីការថែរក្សាបរិស្ថាន (ជីវៈចម្រុះ ទឹក ដី និងខ្យល់)
- លើកកម្ពស់ការអភិវឌ្ឍបរិស្ថាន និងលំនៅឋាន ទាំងក្នុងផ្ទះ ក្រៅផ្ទះ និងជុំវិញផ្ទះឲ្យបានសមរម្យគ្រប់គ្រួសារទូទាំងប្រទេស
- លើកកម្ពស់គុណភាពវិស័យអប់រំ
- លើកកម្ពស់គុណភាពវិស័យសុខាភិបាល
- លើកកម្ពស់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ
- លើកកម្ពស់កិច្ចខិតខំអភិវឌ្ឍវិស័យសង្គមកិច្ចផ្សេងៗទៀត
- កំណត់សូចនាករវាស់វែងវឌ្ឍនភាពនៃការបង្កើនចំណូលរបស់ប្រជាជននិងការអភិវឌ្ឍប្រកបដោយចីរភាព។

## ៦- ផែនការសកម្មភាព

ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់លើសកម្មភាពមួយចំនួន ដូចខាងក្រោមនេះ៖

### ៦.១- ការបង្កើតយន្តការ

ត្រូវពិនិត្យឡើងវិញពីយន្តការនានាដែលបានបង្កើតឡើងរួចហើយ តែនៅខ្វះចន្លោះដែលតម្រូវឲ្យគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ធ្វើបច្ចុប្បន្នកម្មបានត្រឹមត្រូវគ្រប់គ្រាន់ទៅតាមស្ថានភាពបច្ចុប្បន្នសម្រាប់ការអនុវត្តនាពេលខាងមុខ ក្នុងនោះរាជរដ្ឋាភិបាលនឹងបង្កើតយន្តការដូចខាងក្រោម៖

- ពិនិត្យនិងកែសម្រួលការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- បង្កើតក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ ថ្នាក់ក្រសួងស្ថាប័នពាក់ព័ន្ធដែលជាយន្តការសហការសម្របសម្រួលជាមួយនឹងគណៈកម្មាធិការជាតិ ក្នុងការអនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃអំពីវឌ្ឍនភាពនៃការជំរុញចលនាភូមិមួយផលិតផលមួយ

- ពិនិត្យនិងកែសម្រួលការបង្កើតគណៈកម្មាធិការរាជធានី ខេត្តជំរុញចលនាភូមិមួយផលិតផលមួយ ដែលជាបណ្តាញរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ សម្រាប់ធានាដល់ការរៀបចំអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃរាល់ការងារជំរុញចលនាភូមិមួយផលិតផលមួយ ក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្តនីមួយៗ និងរៀបចំបង្កើតអនុគណៈកម្មាធិការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ
- បង្កើតសហគមន៍ ឬសមាគមទ្រទ្រង់ចលនាភូមិមួយ ផលិតផលមួយ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការទទួលស្គាល់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច

### ៦.២- ការបង្កើតក្របខណ្ឌគតិយុត្ត

- គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវចេញសេចក្តីណែនាំ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ នៅតាមក្រសួងស្ថាប័នដែលពាក់ព័ន្ធ
- គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ រាជធានី ខេត្ត និងអនុគណៈកម្មាធិការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ស្ថាប័នទទួលបន្ទុក
- ការបង្កើតសហគមន៍ ឬសមាគមទ្រទ្រង់ចលនាភូមិមួយផលិតផលភូមិមួយ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយសេចក្តីសម្រេចទទួលស្គាល់ពីស្ថាប័នពាក់ព័ន្ធទទួលបន្ទុក។

### ៦.៣- ការគាំទ្រហិរញ្ញវត្ថុ

ដើម្បីអនុវត្តសកម្មភាពគាំទ្រគោលនយោបាយជាតិស្តីពីចលនាភូមិមួយ ផលិតផលមួយ គណៈកម្មាធិការជាតិនិងគណៈកម្មាធិការថ្នាក់ក្រោមជាតិជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវប្រើប្រាស់ថវិកាជាតិ មូលនិធិទ្រទ្រង់ចលនាភូមិមួយផលិតផលមួយ វិភាគទានពីវិស័យឯកជន និងថវិកាមកពីប្រភពផ្សេងៗទៀតដើម្បីជំរុញចលនានេះឱ្យទទួលបានជោគជ័យ។ ក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយតាមក្រសួងស្ថាប័ននានា ត្រូវរៀបចំនិងប្រើប្រាស់គម្រោងថវិកាក្នុងស្ថាប័នរបស់ខ្លួន។

### ៦.៤- ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយ មន្ត្រីតាមក្រសួងស្ថាប័នពាក់ព័ន្ធ មន្ត្រីនៃគណៈកម្មាធិការរាជធានី ខេត្ត និងអនុគណៈកម្មាធិការក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ សហគមន៍សមាគម លើជំនាញផ្សេងៗដែលពាក់ព័ន្ធនឹងការងារការជំរុញចលនាភូមិមួយផលិតផលមួយ។

### ៦.៥- ដំណើរការអនុវត្តគម្រោង

ផែនការជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវរៀបចំប្រចាំឆ្នាំនិងប្រាំឆ្នាំម្តង តាមការប្រជុំពិគ្រោះយោបល់ជាមួយនឹងដៃគូពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ។ ផែនការនេះត្រូវបង្ហាញពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញចលនាភូមិមួយផលិតផលមួយនិងត្រូវឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងឯកសារគតិយុត្តនានារបស់រាជរដ្ឋាភិបាល ហើយផែនការនេះក៏ត្រូវអនុវត្តនៅក្នុងក្របខណ្ឌកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។

## ៧- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីឱ្យការអនុវត្តគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយ ផលិតផលមួយមានប្រសិទ្ធភាពនិងតម្លាភាព ចាំបាច់ត្រូវមានប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងការពិនិត្យកែលម្អក្នុងការអនុវត្តដោយផ្តោតលើ÷

- គោលដៅនិងយុទ្ធសាស្ត្រនៃគោលនយោបាយជាតិ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ
- របាយការណ៍វឌ្ឍនភាពនិងសូចនាករនៃផែនការជាតិ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ
- លទ្ធផលដែលទទួលបានធៀបទៅនឹងគោលដៅដែលបានកំណត់
- ការចូលរួមរបស់គ្រប់ដៃគូពាក់ព័ន្ធទាំងអស់ក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ
- ផលប្រយោជន៍ដែលភូមិឋាន សមាគម ឬសហគមន៍នីមួយៗទទួលបានពីការចូលរួមអនុវត្តចលនាភូមិមួយផលិតផលមួយ។

## ៨- សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវបានឆ្លើយតបទៅនឹងបំណងប្រាថ្នា តម្រូវការ និងលក្ខខណ្ឌចាំបាច់នានារបស់មូលដ្ឋាន ភូមិឋាន រាជធានី ខេត្តនីមួយៗ ដើម្បីបង្កើនផលិតកម្ម បង្កើនវត្ថុធាតុដើម បង្កើនការកែច្នៃឬអភិវឌ្ឍ និងរកទីផ្សារទាំងក្នុងនិងក្រៅប្រទេសក្នុងការលក់ផលិតផល ទាំងផលិតផលជាប្រពៃណីទំនៀមទម្លាប់ និងផលិតផលច្នៃបង្កើតថ្មី ដោយបានបញ្ជាក់ច្បាស់អំពីចក្ខុវិស័យ គោលបំណង និងធនធានសំដៅអភិវឌ្ឍភូមិឋាននីមួយៗនៅទូទាំងប្រទេសដោយចំណូលជាមធ្យមរបស់ប្រជាជននឹងកើនឡើងជាបន្តបន្ទាប់រហូតឈានដល់កម្រិតប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

រាជរដ្ឋាភិបាលសង្ឃឹមនិងជឿជាក់ថា ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល សមាគម សហគមន៍ គ្រួសារ បុគ្គល នឹងចូលរួមគាំទ្រនិងអនុវត្តគោលនយោបាយជាតិនេះឱ្យទទួលបានជោគជ័យ។